**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០២៤ ទសណស

ថ្ងៃចន្ទ ១៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

**ជម្រាបជូន**

- **លោកប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តកែប**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តកំពត**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង**
- **លោកប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីការអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យទេសចរណ៍ជុំទី៧។

**យោង:** សេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចនៅក្នុងបរិការណ៍នៃវិបត្តិ ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ (ជុំទី៧, ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** ជ្រាបថា អនុវត្តតាមសេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចនៅក្នុងបរិការណ៍នៃវិបត្តិ ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩(ជុំទី៧) ក្រសួងទេសចរណ៍សូមណែនាំ លោកប្រធានមន្ទីរទេសចរណ៍ ចុះផ្សព្វផ្សាយ និងជំរុញជាបន្ទាន់ដល់ម្ចាស់អាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍នូវវិធានការមួយចំនួន ដូចខាងក្រោម៖

១. បន្តផ្តល់ប្រាក់ឧបត្ថម្ភ៤០ដុល្លារអាមេរិកក្នុងមួយខែ ជូនកម្មករ-និយោជិត០១នាក់ ដែលបំពេញការងារក្នុងវិស័យទេសចរណ៍ដូចជា៖ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍សម្រាប់រយៈពេល០៣ខែបន្ថែមទៀតពីខែមករា ដល់ខែមីនា ឆ្នាំ២០២១។ សហគ្រាស និងអាជីវកម្មក្នុងវិស័យទេសចរណ៍ត្រូវរួមចំណែកតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមលទ្ធភាពជាក់ស្តែងបន្ថែមលើអ្វីដែលរាជរដ្ឋាភិបាលបានផ្តល់ជូន។

២. បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទចំពោះសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែតសម្រាប់រយៈពេល០៣ខែបន្ថែមទៀតពីខែមករា ដល់ខែមីនា ឆ្នាំ២០២១។ អាជីវកម្មទាំងនេះនៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និងប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែក្នុងអំឡុងពេលនៃការលើកលែងនេះ។

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

៣. បន្តពន្យាការចាប់ផ្ដើមអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធនរយៈពេល០៦ខែបន្តទៀត គឺរហូតដល់ខែកក្កដា ឆ្នាំ២០២១។ ការពន្យាពេលនេះនឹងត្រូវផ្អែកលើការវាយតម្លៃជាបន្តបន្ទាប់នូវស្ថានភាពសង្គម-សេដ្ឋកិច្ចជាក់ស្ដែង។

៤. បន្តលើកលែងការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពនៃបេឡាជាតិសន្តិសុខសង្គមក្នុងអំឡុងពេលព្យួរអាជីវកម្ម ឬផ្អាកដំណើរការអាជីវកម្ម។

៥. បន្តលើកលែងការបង់ពន្ធប៉ាតង់ និងពន្ធលើតែមប្រើសារពើពន្ធ (ពន្ធលើស្លាកយីហោ) ចំពោះក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ដទៃទៀត។ អ្នកជាប់ពន្ធទាំងនេះមានកាតព្វកិច្ចត្រូវធ្វើបច្ចុប្បន្នភាពប៉ាតង់។

៦. កំណត់ឱ្យអ្នកជាប់ពន្ធក្នុងវិស័យទេសចរណ៍ដូចជាៈ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែត ដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២០យ៉ាងយឺតបំផុតឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០២១ ប៉ុន្តែមិនតម្រូវឱ្យបង់ពន្ធគ្រប់ប្រភេទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានមន្ទីរ** ជ្រាប និងអនុវត្ត តាមការគួរ។

សូម **លោកប្រធានមន្ទីរ** ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការប្រចាំការ

**និត ចន្ថា**

**<u>ចម្លងជូនៈ</u>**

- សហព័ន្ធទេសចរណ៍កម្ពុជា (CTF)
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមសណ្ឋាគារកម្ពុជា (CHA)
- សមាគមភោជនីយដ្ឋានកម្ពុជា (CRA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ឯកសារកាលប្បវត្តិ

**<u>ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ</u>**

០៩២ ៧៧៩ ៨៣៣

០៨៩ ៧៦៧ ៦៦៤